# ក្រុមប្រាសាទរាងប្រាំបីជ្រុង

ក្រុមប្រាសាទរាងប្រាំបីជ្រុង គឺជាស្ថាបត្យកម្មប្រាសាទដ៏កម្រនៅក្នុងសិល្បៈខ្មែរ ដែលលេចរូបរាងឡើងនៅរវាងផ្នែកទី១ នៃស.វ.ទី៧ នៅតំបន់ប្រាសាទសំបូរព្រៃគុក ខេត្តកំពង់ធំ និងពុំមាននៅតំបន់ណាផ្សេងទៀតឡើយ។ នៅតំបន់ប្រាសាទសំបូរព្រៃគុក មានប្រាសាទរាងប្រាំបីជ្រុងចំនួន **១៥** តួប៉ម រួមមាន ក្រុមប្រាសាទយាយព័ន្ធមានចំនួន ៦ (តួប៉ម S7, S8, S9, S10, S11, S13) ក្រុមប្រាសាទត្រពាំងរពាក់មានចំនួន ៥ (តួប៉ម Z2, Z3, Z3, Z5, Y1) ក្រុមប្រាសាទសំបូរមានចំនួន ១ (តួប៉ម N7) ក្រុមប្រាសាទតោមានចំនួន ១ (តួប៉ម C7-1) និងប្រាសាទនៅក្នុងបរិវេណក្រុងឦសានចំនួន ២ ទៀត គឺប្រាសាទខ្នាចទោល[១] និងប្រាសាទថ្កាស។ ក្នុងចំណោមប្រាសាទរាងប្រាំបីជ្រុងទាំង ១៤ តួប៉មនេះ មានប្រាសាទចំនួន ៨ ដែលនៅរូបរាងល្អ ហើយប្រាសាទចំនួន ៧ ទៀតបានបាក់បែកនៅសល់តែគ្រឹះប៉ុណ្ណោះ (S13, Z2, Z4, Z5, ប្រាសាទថ្កាស, ប្រាសាទខ្នាចទោល)។

## តើប្រាសាទទាំងនេះមានលក្ខណៈបែបណាខ្លះ?

រាល់ប្រាសាទមានរាងប្រាំបីជ្រុងទាំងអស់ សុទ្ធសឹងសាងឡើងអំពីឥដ្ឋ ប៉ុន្តែការរៀបចំប្លង់ប្រាសាទមានលក្ខណៈផ្សេងៗពីគ្នាខ្លះ។ ជាក់ស្តែង ក្នុងក្រុមប្រាសាទសំបូរ (ក្រុមខាងជើង) ដែលជាក្រុមមានប្រាសាទប្រាំបីជ្រុងតែមួយនោះ យើងឃើញទីតាំងប្រាសាទស្ថិតនៅទិសនិរតីប្រាសាទសំខាន់ដែលនៅតួប៉មកណ្តាល (N1) ពោល គឺគឺមានតួនាទីជាប្រាសាទរណបឱ្យប្រាសាទសំខាន់ដែលតម្កល់សិវលិង្គព្រះនាម "**ស្រីកម្ភីរេស្វរ**" (រូបលេខ១)។ គួរកត់សម្គាល់នោះគឺ ជ្រុងទាំងប្រាំបីរបស់ប្រាសាទនេះមិនស្មើគ្នាឡើយ ហើយយើងក៏ពិបាកសន្និដ្ឋានថា ហេតុអ្វីសិល្បករធ្វើឡើងដូច្នេះដែរ (សូមមើលប្លង់លេខ១)។ តួប៉មប្រាំបីជ្រុងនៅក្រុមខាងជើង (N7) គេតម្កល់ជើងទម្របដិមាមានរាងមូលដែលធ្វើឡើងនៅស.វ.ទី៧ ប៉ុន្តែនៅស.វ.ទី១០ គេបានធ្វើរូបព្រះហៃគ្រីវ ដែលជាអវតារមួយរបស់ព្រះវិស្ណុ (សព្វថ្ងៃបដិមានេះនៅសារមន្ទីរហ្គីមេ បារាំង) (រូបលេខ២)។[២] ដូច្នេះមានន័យថា ប្រាសាទសំខាន់នៅក្នុងក្រុមប្រាសាទសំបូរតម្កល់សិវលិង្គ ប៉ុន្តែប្រាសាទប្រាំបីជ្រុងតម្កល់ព្រះហៃគ្រីវ (ស.វ.ទី១០) ហើយនៅតាមជញ្ជាំងមានលម្អដោយវិមានអណ្តែតគ្រប់ជ្រុង។

ចំណែក ប្រាសាទប្រាំបីជ្រុងនៅក្រុមប្រាសាទយាយព័ន្ធ ឬក្រុមខាងត្បូងវិញ ដើរតួនាទីជាប្រាសាទរណបឱ្យប្រាសាទសំខាន់ដែលនៅតួប៉មកណ្តាលដូចគ្នា។ ប៉ុន្តែ ខុសត្រង់ថា នៅក្រុមនេះ

---

[១] Shimoda and Shimamoto 2012: 55

[២] Lajonquière 1902: 232-233

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

មានប្រាសាទរណបរាងប្រាំបីជ្រុងនៅបរិវេណកំពែងខាងក្នុងចំនួន ៥ ស្ថិតនៅទិសនិរតី ពាយព្យ ឦសាន អាគ្នេយ៍ តួប៉មកណ្ដាល (រូបលេខ៣-៤) និងនៅជ្រុងនិរតីខាងក្រៅកំពែងមានប្រាសាទរាងប្រាំបីជ្រុងចំនួន ១ ទៀត។ ក្នុងចំណោមតួប៉មទាំង ៥ នៅខាងក្នុង មានតែតួប៉ម S9 (រូបលេខ៥) មួយប៉ុណ្ណោះដែលបែរមុខបញ្ច្រាសមកទិសខាងលិច ពោល គឺបែរមុខទល់គ្នាជាមួយតួប៉ម S8 ដែលមើលទៅហាក់ដូចជា តួប៉ម S9 គឺជាមណ្ឌបរបស់តួប៉ម S8 ដ្បិតជាទូទៅសំណង់របស់មណ្ឌបតែងតែបែរមុខទល់គ្នាជាមួយតួប៉មសំខាន់ (ឧទាហរណ៍ តួប៉ម S2 ជាមណ្ឌបរបស់តួប៉ម S1 បែរមុខរកគ្នា) (សូមមើលប្លង់លេខ២)។ ជាអកុសល មានតែតួប៉ម S11 មួយប៉ុណ្ណោះ ដែលមាននៅសល់ជើងទម្ររាងមូលតម្កល់នៅខាងក្នុង រីឯតួប៉មផ្សេងទៀតពុំមានឡើយ ម៉្លោះហើយយើងមិនបានដឹងច្បាស់ថាតើតួប៉មទាំង ៥ នៅខាងក្នុងបរិវេណប្រាសាទយាយព័ន្ធនេះតម្កល់អាទិទេពណាមួយឡើយ។ តួប៉មទាំង ៥ នេះ សុទ្ធសឹងលម្អដោយវិមានអណ្ដែតនៅគ្រប់ជ្រុងដូចប្រាសាទសំបូរតួប៉ម N7 ដែរ។

នៅក្រុមប្រាសាទត្រពាំងរពាក់ ប្រាសាទរាងប្រាំបីជ្រុងតូចៗចំនួន ៤ (បែរមុខទៅជើងនិងត្បូង) ជាប្រាសាទរណបឱ្យប្រាសាទកណ្ដាលដែលមានរាងបួនជ្រុងបែរមុខមកទិសខាងលិច។ យើងក៏មិនដឹងថាតួប៉មទាំង ៤ នេះ តម្កល់អាទិទេពអ្វីឡើយ។ ប៉ុន្តែ នៅខាងលិចប្រាសាទរាងប្រាំបីជ្រុងតូចៗទាំង ៤ នេះ មានប្រាសាទរាងប្រាំបីជ្រុងធំមួយបែរមុខទៅទិសខាងកើត (រូបលេខ៦)។ ផ្ទុយពីខាងលើ នៅក្រុមប្រាសាទតោ ប្រាសាទរាងប្រាំបីជ្រុងគេសាងនៅខាងក្រៅកំពែង ដែលសង់ស្របគ្នាជាមួយតួប៉ម ៣ ផ្សេងទៀត ហើយប្រាសាទប្រាំបីជ្រុងនៅខាងត្បូងបង្អស់ បែរមុខទៅទិសខាងកើត។ រីឯនៅក្រុមប្រាសាទខ្ចាចទោល ប្រាសាទរាងប្រាំបីជ្រុងគេសង់នៅទិសអាគ្នេយ៍ដាច់ដោយឡែកតែឯងពីប្រាសាទចំនួនបីមានរាងបួនជ្រុងស្មើ។

## តើប្រាសាទរាងប្រាំបីជ្រុងតំណាងឱ្យអ្វី? សិល្បករសាងឡើងដើម្បីអ្វី? មានឥទ្ធិពលពីខាងណា?

យើងពិតជាពិបាកកំណត់អំពីតួនាទីប្រាសាទរាងប្រាំបីជ្រុងយ៉ាងខ្លាំង បើទោះបីសិល្បៈខ្មែរកាលជំនាន់នោះទទួលឥទ្ធិពលសិល្បៈពីឥណ្ឌាក៏ដោយ ដ្បិត នៅស្រុកឥណ្ឌាផ្ទាល់ពុំសូវមានប្រាសាទមានរាងប្រាំបីជ្រុងនៅមុនស.វ.ទី៧ ឡើយ ពោល គឺមានតែប្រាសាទ Muṇḍeçvarī មួយប៉ុណ្ណោះ ដែលជាប្រាសាទរាងប្រាំបីជ្រុងសាងសង់រួចរាល់នៅរវាងគ.ស.ឆ្នាំ៦៣៥-៦៣៦។[៣] កាលបរិច្ឆេទរបស់ប្រាសាទនេះ មានលក្ខណៈប្រហាក់ប្រហែលជាមួយឆ្នាំកសាងប្រាសាទនៅសំបូរព្រៃ

[៣] Neuss 2003: 535

អត្ថបទដោយ៖ ម៉ង់ វ៉ាលី

*គុកដែរ ពោល គឺស្ថិតនៅក្នុងរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ (គ.ស.៦១៦-៦៣៧)។ ចំណែកទម្រង់របស់ប្រាសាទនៅឥណ្ឌានេះក៏មានរូបរាងស្រដៀងប្រាសាទរបស់ខ្មែរដែរ ពិសេស គឺមានលម្អវិមានអណ្ដែតនៅតាមជញ្ជាំងដូចគ្នា (រូបលេខ៧)។ ប៉ុន្តែ ប្លង់ប្រាសាទឥណ្ឌាខុសពីយើងត្រង់ថា គេមានទ្វារចេញចូលចំនួន ៤ រីឯប្រាសាទខ្មែរមានទ្វារតែខាងកើតមួយគត់ (សូមមើលប្លង់លេខ៣)។ ដូច្នេះ យើងមិនអាចកំណត់បានថា ការសាងសង់ប្រាសាទរាងប្រាំបីជ្រុងរបស់ខ្មែរ ពិតជាទទួលឬមិនទទួលឥទ្ធិពលពីឥណ្ឌាមែនឬអត់ឡើយ។ អ្វីដែលយើងអាចសន្និដ្ឋានបាននោះគឺ ការសាងសង់នេះ ទំនងជាត្រាប់តាមគម្ពីរណាមួយនៃព្រហ្មញ្ញសាសនា ជាពិសេស គឺទាក់ទងនឹងការរៀបចំប្លង់ប្រាសាទឧទ្ទិសដល់ព្រះឥសូរ ដ្បិតលេខ ៨ ត្រូវនឹងទម្រង់របស់ព្រះឥសូរមាន ៨ ធំៗ គឺ ដី ស៌រ្វ ( śarva) ដី ភវ (Bhava) ទឹក រុទ្រ (Rudra) ភ្លើង ឧគ្រ (Ugra) ខ្យល់ ភីម (Bhīma) លំហ បសុបតិ (Paśupati) ព្រលឹង ឥសាន (Īśāna) ព្រះអាទិត្យ មហាទេវ (Mahādeva) ព្រះច័ន្ទ។ លើសពីនេះទៀត ការបែងភាគ ឬបដិហាររបស់ព្រះឥសូរ តែងបែងភាគពី ៨ ទៅ ៦៤។ ការសន្និដ្ឋាននេះស្របទៅតាមសិលាចារឹកដែលរកឃើញនៅក្រុមប្រាសាទយាយព័ន្ធដែលបង្ហាញថា តួប៉មកណ្ដាល តម្កល់ព្រះឥសូរក្នុងទម្រង់ជាសិវលិង្គព្រះនាម* ***"ស្រីប្រហសិតេស្វរ"*** *(សិវញញឹម)* *(Çrīprahasiteçvara)* (K.440, K.442)[៨] *និងក្រុមប្រាសាទសំបូរ សិវលិង្គព្រះនាម* ***"ស្រីកំម្ភីរេស្វរ"*** *(Çrīkaṃmbhĭreçvara)* (K.148, K.439)*។*[៩]

*ជារួមមក ក្រុមប្រាសាទរាងប្រាំបីជ្រុងនៅក្នុងសិល្បៈខ្មែរ គឺជាស្ថាបត្យកម្មដ៏មានវិសេសវិសាលមួយនៅស.វ.ទី៧ ហើយយើងមិនដឹងថាហេតុអ្វីសំណង់បែបនេះគេលែងបន្តសាងសង់នៅសម័យក្រោយៗមកទៀតទេ។ សំណង់ប្រាសាទប្រាំបីជ្រុងនៅសំបូរព្រៃគុក ទំនងសង់ត្រាប់តាមគម្ពីរណាមួយនៃព្រហ្មញ្ញសាសនា ហើយប្រហែលជាប់ទាក់ទងនឹងការរៀបចំប្លង់ប្រាសាទឧទ្ទិសដល់ព្រះឥសូរ។ ដ្បិត តួប៉មកណ្ដាលនៃក្រុមប្រាសាទសំខាន់នៅតំបន់សំបូរព្រៃគុកសុទ្ធសឹងឧទ្ទិសដល់ព្រះឥសូរ ម៉្លោះហើយ សំណង់ប្រាសាទប្រាំបីជ្រុងអាចជាគំនិតមួយដែលខ្មែរជំនាន់នោះសាងឡើងសម្រាប់បង្ហាញអំពីទម្រង់និងការបែងភាគរបស់ព្រះឥសូរដែលចេញតួប៉មកណ្ដាល ឬម្យ៉ាងទៀត ប្រាសាទប្រាំបីជ្រុងអាចគេសាងសង់ឡើង សម្រាប់តម្កល់អាទិទេពផ្សេងៗទៀតដែលមានអានុភាពទាបជាងព្រះឥសូរ ជាក់ស្ដែងដូចប្រាសាទ* N7 *ដែលតម្កល់ព្រះហៃគ្រីវជាតឹកតាង។*

---

[៨] Cœdès 1952: 5-11.

[៩] Cœdès 1952: 33.



ប្លង់លេខ១៖ ប្លង់បាតប្រាសាទសំបូរ តួប៉ម N7
(ប្រភព៖ គម្រោងអភិរក្សសំបូរព្រៃគុក)



រូបលេខ២៖ ប្រាសាទសំបូរ តួប៉ម N7

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៣៖ បដិមាព្រះហៃគ្រីវ តម្កល់នៅប្រាសាទសំបូរ តួប៉ម N7



រូបលេខ៤៖ ប្រាសាទយាយព័ន្ធ តួប៉ម S7



រូបលេខ៥៖ ប្រាសាទយាយព័ន្ធ តួប៉ម S11

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៦៖ ប្រាសាទយាយព័ន្ធ តួប៉ម S9




ប្លង់លេខ២៖ ប្លង់ក្រុមប្រាសាទយាយព័ន្ធ បង្ហាញអំពីប្រាសាទរាងប្រាំជ្រុងទាំង៩ នៅរណបតួប៉មកណ្តាល

(ប្រភព៖ លោក ឯម គឹមស្រ៊ាង)

អត្ថបទដោយ៖ ម៉ង់ វ៉ាលី



រូបលេខ៧៖ ប្រាសាទត្រពាំងរពាក់ តួប៉ម Y1



រូបលេខ៨៖ ប្រាសាទ *Muṇḍeçvarī* នៅខេត្ត Bihar ឥណ្ឌាភាគខាងកើត (ប្រភព៖ Neuss)




ប្លង់លេខ៣៖ ប្លង់បាតប្រាសាទ *Muṇḍeçvarī* ខេត្ត Bihar ឥណ្ឌាភាគខាងកើត

(ប្រភព៖ Neuss)

## ឯកសារយោង

**Coedès, George**

1952, *Inscription du Cambodge*, Vol IV, Hanoi

**Ichita Shimoda and Sae Shimamoto**

2012, *"Spatial and chronological Sketch of the ancient city of Sambor Prei Kuk"*, Aśeanie 30, décembre 2012.

**Jurgen Neuss**

2003, *"The temple of Muṇḍeśvarī",* Berliner indologische studien (BIS) 15/16/17

**Lunet De Lajonquière**

1902, *Inventaire descriptive des monuments du Cambodge*, Tome I, Paris